# អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងបញ្ហាប្រឈមនៃរបប "កូនកាត់"

***Caroline Hughes, Joakim Öjendal** និង ប៉ក់ គីមជឿន ពិភាក្សាពីការវិវត្តន៍ទស្សនៈនៃប្រជាធិបតេយ្យភាវូបនីយកម្ម និងគោលគំនិតនៃរបបកូនកាត់ នៅក្នុងប្រព័ន្ធអភិបាលកិច្ច ។**

អត្ថបទនេះបង្ហាញពីគោលគំនិតនៃរបបកូនកាត់ (hybridity) ដែលសំដៅដល់របបអភិបាលកិច្ចមួយមានគួបផ្សំគ្នានូវ សមាសធាតុផ្សេងៗនៃរបបផ្តាច់ការ និងរបបប្រជាធិបតេយ្យ (Karl 1995) ។ អត្ថបទចាប់ផ្តើមបង្ហាញពីការវិវត្តន៍គោលគំនិតស្តីពីប្រជាធិបតេយ្យភាវូបនីយកម្ម បន្ទាប់មកគឺ ប្រព័ន្ធអភិបាលកិច្ចបែបកូនកាត់ដែលមានវែកញែកពិភាក្សាក្នុងឯកសារផ្សេងៗ ។ បន្ទាប់មកទៀត អត្ថបទពិចារណាថា តើរបបកូនកាត់នេះអាចដាក់អនុវត្តយ៉ាងណាបានក្នុងបរិបទអភិបាលកិច្ចនៅកម្ពុជា ជាពិសេសក្នុងកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលទើបដំណើរការនេះ ដើម្បីយកធ្វើជាក្របខ័ណ្ឌនៃការស្រាវជ្រាវបែបវិភាគរបស់ផ្នែកអភិបាលកិច្ច និងវិមជ្ឈការនៃវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ) សំរាប់ដំណាក់កាលថ្មីនៃកម្មវិធីពីឆ្នាំ២០០៧ ដល់ ២០១០ ។

## រលកទី៣

នៅចុងទសវត្សរ៍១៩៨០ និងដើមទសវត្សរ៍១៩៩០ គេនិយាយថា មានរលកទី៣នៃប្រជាធិបតេយ្យភាវូបនីយកម្ម បានបោកបក់លើពិភពលោក (Huntington 1991) ។ បណ្តាប្រទេសនៅអឺរ៉ុបខាងត្បូង អាមេរិកឡាទីន អឺរ៉ុបខាងកើត អាហ្វ្រិក និងអាស៊ី បានចាប់ផ្តើមទទួលយកប្រព័ន្ធពហុបក្សតាមបែបណាមួយ ។ ក្នុងរលកនេះ ការរីកសាយលទ្ធិប្រជាធិបតេយ្យមានលក្ខណៈពិសេសថ្មី ២ ។ Huntington (1991) បានលើកថា កត្តាសាកល (ជាជាងកត្តាក្នុងតំបន់) មានចំនែកសំខាន់នៅក្នុងកំលាំង និងវិសាលភាពនៃការរីករាលដាលលទ្ធិប្រជាធិបតេយ្យ រីឯការសិក្សាដ៏សំខាន់របស់ O'Donnell និង Schmitter (1986) ស្តីពី *អន្តរកាលចេញពីរបបផ្តាច់ការ* បានធ្វើឱ្យការសិក្សាពីប្រជាធិបតេយ្យភាវូបនីយកម្ម ប្រែប្រួលក្រឡាប់ចក្រ ដោយសង្កត់ធ្ងន់ពីសារៈសំខាន់នៃ "កិច្ចព្រមព្រៀងរបស់ពួកឋានៈខ្ពស់" ជាជាងកំណើននៃកំលាំងសង្គមដែលគាំទ្រលទ្ធិប្រជាធិបតេយ្យ ក្នុងការពន្លឿនអន្តរកាលទៅកាន់របបប្រជាធិបតេយ្យ ។

គំនិតដែលថា អន្តរកាលទៅកាន់របបប្រជាធិបតេយ្យ អាចត្រូវបានរៀបចំ និងអនុវត្តតាមរយៈសកម្មភាពដោយចេតនារបស់អ្នកឋានៈខ្ពស់ ដើម្បីឆ្លើយតបទៅនឹង "ឥទ្ធិពលនៃការបកស្រាយបង្ហាញ" ជាលក្ខណៈអន្តរជាតិ គឺជាគំនិតថ្មីប្លែកមួយនៅក្នុងវិទ្យាសាស្ត្រនយោបាយ ដែលជាយូរមកហើយតែងផ្តោតលើរចនាសម្ព័ន្ធត្រូវមានជាមុន និងតំរូវការរយៈពេលវែង (Di Palma 1990; Lipset 1969; Moore 1968) ។ ការយកចិត្តទុកដាក់លើកិច្ចព្រមព្រៀងរបស់ពួកឋានៈខ្ពស់ បានបំផុសកម្មវិធីស្រាវជ្រាវថ្មីៗ ដែលមិនសូវផ្តោតលើបញ្ហាការវិវត្តន៍នៃកំលាំងសង្គមគាំទ្រលទ្ធិប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋានទេ ប៉ុន្តែផ្តោតខ្លាំងទៅលើវិធីដែលពួកឋានៈខ្ពស់ក្នុងប្រទេសកំពុងកសាងរបបប្រជាធិបតេយ្យ បានប្រើប្រាស់អំណាចរបស់ខ្លួន ដើម្បីគាំទ្រ រឺធ្វើឱ្យអន្តរាយដល់ស្ថាប័នដែលបានកសាង រឺកែទំរង់ស្របទៅតាមបញ្ញត្តិនានានៃគោលនយោបាយអន្តរជាតិ ។

ក្នុងវិស័យគោលនយោបាយ ទ្រឹស្តីថ្មីៗស្តីពីប្រជាធិបតេយ្យភាវូបនីយកម្ម បានគាំទ្រដល់ការលើកកំពស់លទ្ធិប្រជាធិបតេយ្យនៅក្នុងនយោបាយពួកបស្ចឹមប្រទេសធំៗ ។ ប្រជាធិបតេយ្យភាវូបនីយកម្ម ដែលក្លាយជាគោលដៅរបស់ពួកបរទេស និងនយោបាយផ្តល់ជំនួយ វាផុសចេញពីនិក្ខេបបទពីរដែលពាក់ព័ន្ធគ្នា ។ និក្ខេបបទទី១ អះអាងថា ការបង្កើតស្ថាប័នប្រជាធិបតេយ្យនៅថ្នាក់កំពូល នឹងជួយលើកកំពស់នយោបាយប្រជាធិបតេយ្យនៅថ្នាក់ក្រោម ទោះបី "វប្បធម៌នយោបាយប្រជាធិបតេយ្យ" មិនទាន់មាននៅឡើយក្តី ។ លោក Luckham, Goertz និង Kaldor (2003) បានពន្យល់ពីរឿងនេះដោយញែកដាច់ពីគ្នារវាង "ស្ថាប័នប្រជាធិបតេយ្យ" និង "នយោបាយប្រជាធិបតេយ្យ" ។ ស្ថាប័នប្រជាធិបតេយ្យ គឺមានអង្គភាពទទួលបន្ទុកលើការបោះឆ្នោត ក្រុមជំនុំ និងភាគីនានាដែលយល់ដឹងច្រើនពីគោលនយោបាយលើកកំពស់លទ្ធិប្រជាធិបតេយ្យ ។ នយោបាយប្រជាធិបតេយ្យ ផ្តោតលើបរិបទនយោបាយដែលក្នុងនោះស្ថាប័នប្រជាធិបតេយ្យត្រូវដំណើរការ និងដែលជាបរិបទនៃរចនាសម្ព័ន្ធមិនផ្លូវការនៃអំណាច អង្គភាពនានានៃសហគមន៍មូលដ្ឋាន កំលាំងសង្គមមិនមែនរដ្ឋ ហើយអាចមានទាំងកំលាំងសង្គមមិនមែនជាតិទៀតផង ។ អ្នកកសាងទ្រឹស្តីអំពីអន្តរកាលបានអះអាងថា ការរចនាតាក់តែងស្ថាប័នថ្មីមួយ ទាមទារការកែប្រែឥរិយាបថខាងនយោបាយរបស់ប្រជាជន ដែលត្រូវសំរបយុទ្ធសាស្ត្រនយោបាយរបស់ខ្លួនឱ្យកាន់តែច្រើនឡើងទៅតាមក្បួន "ល្បែង" ប្រជាធិបតេយ្យ (O'Donnell and Schmitter 1986) ។ នៅពេលដែលតួអង្គនយោបាយ "មានទំលាប់" គ្រប់គ្រាន់ ជាមួយនឹងក្បួនទាំងនេះ ហើយលទ្ធិប្រជាធិបតេយ្យ បានក្លាយជា "ល្បែងតែមួយដែលមាននៅក្នុងស្រុកភូមិ" ការពង្រឹងលទ្ធិប្រជាធិបតេយ្យមុខតែនឹងកើតមាន (Linz and Stepan 1997) ។ ក្នុងរលកសុទិដ្ឋិនិយមដែលផុសឡើងនៅចុងបញ្ចប់នៃសង្គ្រាមត្រជាក់ ការពង្រឹងលទ្ធិប្រជាធិបតេយ្យច្រើនតែជាលទ្ធផលធម្មតាៗនៃអន្តរកាលប្រជាធិបតេយ្យ ប៉ុន្តែក៏អាចមានការវិវត្តន៍ "បញ្ច្រាស" ដែរ ដោយសារអន្តរាគមន៍យោធាដែលកើតមានជាថ្មី ។

និក្ខេបបទទី២ ដែលលើកកំពស់គោលនយោបាយជំរុញ លទ្ធិប្រជាធិបតេយ្យ គឺជានិក្ខេបបទសន្តិភាពប្រជាធិបតេយ្យ ។ និក្ខេបបទនេះផ្សារភ្ជាប់លទ្ធិប្រជាធិបតេយ្យទៅនឹងសន្តិភាព ដោយផ្អែកតាមការអះអាងរបស់ Kantian ដែលថា តួអង្គដែលមានវិចារណញ្ញាណផ្ទាល់ខ្លួន នឹងមិនធ្វើសង្គ្រាមទេ ពីព្រោះវាមិនស្របនឹងផលប្រយោជន៍របស់ពួកគេ ហើយរបបប្រជាធិបតេយ្យ គឺជាទំរង់មួយនៃរដ្ឋាភិបាលដែលរក្សាការពារបានប្រសើរ

* អត្ថបទនេះ ផ្អែកលើទស្សនៈ "កូនកាត់" ដែលជាក្របខ័ណ្ឌស្រាវជ្រាវដ៏មានប្រយោជន៍សំរាប់កម្មវិធីកំណែទំរង់វិស័យសាធារណៈ និងអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនៃ វបសអ ។ លោកស្រី Caroline Hughes ជាសាស្ត្រាចារ្យនៅមហាវិទ្យាល័យវិទ្យាសាស្ត្រនយោបាយ និងការសិក្សាអន្តរជាតិនៃសាកលវិទ្យាល័យ Birmingham ប្រទេសអង់គ្លេស ។ លោក Joakim Öjendal ជាសាស្ត្រាចារ្យនៅមហាវិទ្យាល័យស្រាវជ្រាវខាងសន្តិភាព និងអភិវឌ្ឍន៍នៃសាកលវិទ្យាល័យ Goteborg ប្រទេសស៊ុយអែត លោក ប៉ក់ គីមជឿន ជាអ្នកស្រាវជ្រាវនៅ វបសអ ។

បំផុតនូវស្វយភាពរបស់តួអង្គមានវិចារណញ្ញាណ ។ ឧទាហរណ៍ លោក Boutros Boutros-Ghali អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ក្នុង *របៀបវារៈដើម្បីសន្តិភាព* ឆ្នាំ១៩៩២ របស់លោក បានផ្អែកតាមទ្រឹស្ដីសន្តិភាពប្រជាធិបតេយ្យរបស់ Kantian នេះ ដើម្បីអះអាងថា:

> *"មានទំនាក់ទំនងជាក់ស្ដែងរវាងរបៀបរបបប្រជាធិបតេយ្យ ដូចជា នីតិរដ្ឋ និងតំលាភាពក្នុងការធ្វើសេចក្ដីសំរេចចិត្តជាដើម ហើយនិង ការទទួលបានសន្តិភាព និងសន្តិសុខពិតៗនៅក្នុងរបបនយោបាយថ្មី និងមានស្ថិរភាពល្អណាមួយ "(Boutros-Ghali, 1995) ។*

ក្នុងពេញមួយទសវត្សរ៍១៩៩០ ដំណោះស្រាយរឿងនយោបាយកាន់តែស្មុគស្មាញ ដែលជំរុញដោយអង្គការអន្តរជាតិដើម្បីដោះស្រាយសង្គ្រាមស៊ីវិលនានា បានដាក់បញ្ចូលការងារលើកកំពស់លទ្ធិប្រជាធិបតេយ្យ ជាពិសេសការបោះឆ្នោតពហុបក្ស ដើម្បីធ្វើជាមធ្យោបាយសំរាប់ពង្រឹងសន្តិភាព ។ ការបារម្ភក្នុងចំណុចនេះ បានបំប្លែងការលើកកំពស់លទ្ធិប្រជាធិបតេយ្យ ឱ្យទៅជាយុទ្ធសាស្ត្រសន្តិសុខជាតិយ៉ាងចំហមួយសំរាប់ពួកបស្ចិមប្រទេស (Evans, 1994) ។

គោលជំហរនេះ បានជំរុញឱ្យមានការបញ្ជូនទីប្រឹក្សាខាងលទ្ធិប្រជាធិប-តេយ្យ ទៅជួយរដ្ឋាភិបាលនានានៅទូទាំងពិភពលោក ក្នុងការតាក់តែងច្បាប់ បង្កើតស្ថាប័ន និងរៀបចំការបោះឆ្នោត ។ និន្នាការនេះ ដែលសង្គ្រាមត្រជាក់បានជួយពង្រឹងឡើង វាត្រូវដោះស្រាយជំលោះផ្ទៃក្នុងជាច្រើន និងបង្កើតឡើងវិញនូវរដ្ឋាភិបាល ដែលអាចធ្វើការងារបាន ព្រមទាំងគោរពសិទ្ធិមនុស្ស និងប្រឹងប្រែងកសាងលទ្ធិប្រជាធិបតេយ្យ ។ ជារឿយៗ រឿងនេះធ្វើឡើងតាមរយៈអន្តរាគមន៍ពីអន្តរជាតិដើម្បី "ដាក់បញ្ចូល" ទៅក្នុងប្រព័ន្ធនយោបាយនានានូវនីតិវិធីប្រជាធិបតេយ្យ ដែលបានមកពីខាងក្រៅ និងមកពីថ្នាក់លើ (e.g. Doyle and Orr 1996) ។ ការបោះឆ្នោតក្រោយពេលបញ្ចប់សង្គ្រាមស៊ីវិល ដើម្បីផ្ដល់ភាពស្របច្បាប់ដល់របបដឹកនាំមានរដ្ឋធម្មនុញ្ញ បានក្លាយជាលក្ខណៈសំគាល់មួយនៃសឹងតែគ្រប់ដំណើរការកសាងសន្តិភាពដែលជួយឧបត្ថម្ភដោយអន្តរជាតិក្នុងទសវត្សរ៍១៩៩០ ។

## និយមន័យប្រជាធិបតេយ្យ

បញ្ហាមួយក្នុងការលើកកំពស់លទ្ធិប្រជាធិបតេយ្យ នៅក្រោយសម័យសង្គ្រាមត្រជាក់ គឺការកំណត់និយមន័យលទ្ធិប្រជាធិបតេយ្យ ។ ក្នុងការសិក្សាឯកសារខាងទ្រឹស្ដី មានការចាត់ទុកជាទូទៅថា "លទ្ធិប្រជាធិបតេយ្យ" គឺជា "ទស្សនៈមួយដែលមានការជជែកតវ៉ាច្រើន" ។ គេមិនអាចកំនត់និយមន័យនេះឱ្យបានគួរជាទីពេញចិត្តទេ ពីព្រោះវាបង្ហាញពីការវាយតំលៃផង និងការពិពណ៌នាផង (Gallie 1956) ។ ប៉ុន្តែការយកចិត្តទុកដាក់លើកកំពស់ និងវាយតំលៃលទ្ធិប្រជាធិបតេយ្យនៅជុំវិញពិភពលោក បានជំរុញឱ្យមានការប្រើប្រាស់ជាទូទៅនូវនិយមន័យសាមញ្ញៗក្នុងទសវត្សរ៍១៩៩០ ។ អន្តរកាលប្រជាធិបតេយ្យ មាននិយមន័យថាជាដំណើរការមួយដែលក្នុងនេះ ស្ថាប័នដែលធ្វើការគ្រប់គ្រងតាមបែបផ្ដាច់ការ រឺកុម្មុយនីស្ត ត្រូវបានជំនួស ឬកែទំរង់ ដើម្បីឱ្យស្របទៅតាមការតំរូវឱ្យមានរបបពហុបក្សមួយក៏រិត ដែលមានដាក់បញ្ចូលលទ្ធភាពជ្រើសរើសអ្នកតំណាង លទ្ធភាពចូលរួមកសាងរបៀបវារៈនយោបាយ និងការគោរពសិទ្ធិពលរដ្ឋ សិទ្ធិខាងនយោបាយ និងសេរីភាព ។ ទស្សនៈ "ខ្នាតតូច" នៃលទ្ធិប្រជាធិបតេយ្យនេះ ដែលយកចេញពីការកំណត់របស់ Dahl ដែលថា "របបពហុបក្ស" ត្រូវមានជំរើស ការចូលរួម និងការគោរពសិទ្ធិមនុស្ស (Dahl 1971) វាបានដើរតួជានិយមន័យស្នូលសំរាប់អ្នកកសាងគោលនយោបាយអន្តរជាតិនានា ដោយពុំចាំបាច់មានការពិភាក្សាវែកញែកច្រើនទេ ។

ការសង្កត់ធ្ងន់លើវិធាន នីតិវិធី និងស្ថាប័ននានា ជាជាងលើវប្បធម៌ គុណតំលៃ និងក្រឹត្យក្រមនៃការធ្វើអន្តរកម្ម បានញុំាងឱ្យការសិក្សាពីអន្តរកាលនានាក្លាយជាលែងមានបញ្ហាចោទ ពីព្រោះវាផ្ទេរការពិបាកផ្សេងៗក្នុងការបង្ហាញពីនយោបាយប្រជាធិបតេយ្យកាន់តែទូលំទូលាយ ទៅកាន់ដំណាក់កាលក្រោយនៃ "ការពង្រឹង" វិញ (Luckham etal. 2003:15") ។ ប៉ុន្តែនិយមន័យតាមបែបនីតិវិធីនៃលទ្ធិប្រជាធិបតេយ្យនេះ ត្រូវបានគេទិតៀនក្នុងពីរចំណុច ។ ទី១ វាកាត់ផ្ដាច់ការចូលរួមធ្វើនយោបាយជាផ្លូវការចេញពីបញ្ហាយុត្តិធម៌ក្នុងសង្គមដ៏សំខាន់ ។ ទី២ និយមន័យទាំងនេះច្រើនតែបញ្ចេញប្រើដោយមានយោងតិចតួចទៅដល់ការពិតជាក់ស្ដែងដែលថា នៅក្នុងរបបប្រជាធិបតេយ្យដែលចាក់ឫសរឹងមាំនៃបស្ចិមប្រទេស នីតិវិធីផ្លូវការច្រើនមានដំណើរការមិនល្អទេ ក្នុងការកេណ្ឌប្រមូលការចូលរួមខាងនយោបាយដ៏ផុសផុលដោយមានការយល់ដឹងគ្រប់គ្រាន់ ។

## របបកូនកាត់ ក្នុងលក្ខណៈជាលទ្ធផលអន្តរកាលមួយបែបផ្សេង

ក្រៅពីបញ្ហាកំណត់និយមន័យលទ្ធិប្រជាធិបតេយ្យ ការពិតជាក់ស្ដែងក្នុងទសវត្សរ៍១៩៩០ ក៏បានចោទបញ្ហាដល់លំនាំនៃអន្តរកាលដែរ ។ គំនិតដែលថាបណ្ដាស្ថាប័នប្រជាធិបតេយ្យតាមបែបពីលើចុះក្រោម នឹងបង្កឱ្យមាននយោបាយប្រជាធិបតេយ្យតាមបែបពីក្រោមឡើងលើវិញ គឺហាក់ដូចមិនសូវពិតសោះនៅក្នុងការអនុវត្តន៍ជាក់ស្ដែង ។ ខណៈដែលប្រទេសមួយចំនួនតូចដែលធ្វើអន្តរកាលតាម "រលកទី៣" បានក្លាយជាប្រទេសមានប្រជាធិបតេយ្យដ៏ពេញលេញ ក៏មានប្រទេសជាច្រើនដែលបានជាប់ផុងនៅក្នុង "តំបន់ប្រផេះ" រឺក៏ "របបកូនកាត់" រឺ "ប្រជាធិបតេយ្យពាក់កណ្ដាល" រឺ "ប្រជាធិបតេយ្យក្លែងក្លាយ" ដែលមានគួបផ្សំ "សមាសធាតុនានានៃរបបផ្ដាច់ការ និងរបបប្រជាធិបតេយ្យ" (Karl 1995) ។ នៅក្នុងតំបន់ប្រផេះទាំងនេះ ទំរង់ផ្សេងៗនៃអន្តរកម្មនយោបាយ ដែល (បើគិតតាមទស្សនៈលើកកំពស់លទ្ធិប្រជាធិបតេយ្យ) ហាក់ដូចជា "ល្ងិតល្ងង់ខ្លាំងណាស់" ក៏បែរជានៅស្ថិតស្ថិរបានយូរគួរសម (Carothers 2002; Inoguchi and Bacon 2003) ។ នៅក្នុងរបបប្រជាធិបតេយ្យកូនកាត់ ចរិតប្រជាធិបតេយ្យនៃស្ថាប័ននានា មិនបានបង្កើតចេញនូវនយោបាយប្រជាធិបតេយ្យនៅស្រទាប់ក្រោមនោះទេ ហើយគេបានផ្ដល់សេចក្ដីពន្យល់មួយចំនួនដូចតទៅ ។

***ភាពមិនស្មោះត្រង់យ៉ាងផ្ដាច់ការ:*** ការធ្វើអន្តរកាលមួយចំនួនត្រូវបានគេចាត់ទុកថាជារឿងសើៗតែសំបកក្រៅ ដែលក្នុងនោះពួកឋានៈខ្ពស់បានផ្ដល់សេរីភាវូបនីយកម្មមួយក៏រិត ដើម្បីសំរាលការព្រួយបារម្ភរបស់អ្នកផ្ដល់ជំនួយ ប៉ុន្តែខំធ្វើយ៉ាងណាឱ្យស្ថាប័នប្រជាធិបតេយ្យនានា មានតួនាទីតូចតាចដដែល នៅក្នុងការងារនយោបាយពិតៗ ដូច្នេះហើយវាមិនអាចប្រើប្រាស់សំរាប់ពង្រឹងនយោបាយប្រជាធិបតេយ្យនៅថ្នាក់ក្រោមបានទេ ។

***ឆន្ទៈនយោបាយអន្តរជាតិមិនគ្រប់គ្រាន់:*** ការសិក្សាជាច្រើនបានថ្កោលទោសតួអង្គអន្តរជាតិដែលមិនបានផ្ដល់ធនធាន និងការយកចិត្តទុកដាក់គ្រប់គ្រាន់ ដើម្បីជំរុញសន្ទុះប្រជាធិបតេយ្យនៅប្រទេសជាក់លាក់មួយចំនួន ។

***វប្បធម៌មិននយោបាយមិនសមស្រប រឺខុសគ្នា:*** កត្តាខាងវប្បធម៌ ដែលជួយពង្រឹងលទ្ធិប្រជាធិបតេយ្យមួយចំនួន ដូចជា របបប្រជាធិបតេយ្យបែបផ្ទេរសិទ្ធិ (O'Donnel 1995) ហើយនិងរបបប្រជាធិបតេយ្យបែបអាស៊ី (Neher 1993) ត្រូវបានគេចាត់ទុកថា ជាលទ្ធផលនៃកង្វះខាតវប្បធម៌នយោបាយប្រជាធិបតេយ្យសំរាប់បំពេញបន្ថែមលើស្ថាប័នប្រជាធិបតេយ្យនានា ។ វប្បធម៌ឆ្លើយតបទៅនឹង "ស្នេហ៍មុខ"របស់បុគ្គល បានជំរុញអ្នកបោះឆ្នោតនៅអាមេរិកឡាទីន ឱ្យបោះឆ្នោតឱ្យបុរសខ្លាំង (តាមទ្រឹស្តីរបស់ O'Donnel) រីឯការគោរពដល់ឋានានុក្រម និងការផ្តល់អាទិភាពដល់ស្ថិរភាពសហគមន៍ជាជាងឱកាសល្អរបស់បុគ្គលម្នាក់ៗ បានបង្កើតជាប្រព័ន្ធគណបក្សស្ទៀមស្ទឹកដែលកាត់បន្ថយសេរីភាពមួយចំនួននៅអាស៊ី (យោងតាម Neher) ។

***ចំណាប់អារម្មណ៍មិនសមស្របចំពោះសហគមន៍នយោបាយ:*** Luckham *et al.* (2003) បានវែកញែកថា "បញ្ហាសំខាន់ក្នុងរយៈពេលវែង" គឺ តើត្រូវធ្វើយ៉ាងណាដើម្បីរៀបចំកំលាំងមិនមែនរដ្ឋទាំងនេះឱ្យទៅជា "សហគមន៍នយោបាយតែមួយដែលឈរលើការព្រមព្រៀងយ៉ាងទូលំទូលាយ និងទស្សនៈរាប់បញ្ចូលជាមួយគ្នានៃភាពជាពលរដ្ឋរួមគ្នា" ដែលត្រូវមានជាចាំបាច់សំរាប់អភិបាលកិច្ចបែបប្រជាធិបតេយ្យ ។ តាមរយៈការអះអាងបែបនេះ អ្នកនិពន្ធបានផ្តល់គំនិតថា បញ្ហាដ៏ធំបំផុត គឺការបែកបាក់គ្នាក្នុងសង្គមដោយសារចំណងទាក់ទងខាងជនជាតិ រឺនិន្នាការនយោបាយ ។ រឿងនេះធ្វើឱ្យមានការផាត់ចេញពីស្ថាប័នប្រជាធិបតេយ្យជាតិជាផ្លូវការ ដែលមិនសូវមានការពាក់ព័ន្ធច្រើននឹងជីវភាពរស់នៅប្រចាំថ្ងៃ ។

***ប្រភេទមិនសមស្របនៃលទ្ធិប្រជាធិបតេយ្យដែលត្រូវបានជំរុញឡើង:*** Gills and Rocamora (1997) វែកញែកថា ទស្សនៈខ្នាតតូចនៃលទ្ធិប្រជាធិបតេយ្យ ដែលត្រូវបានជំរុញឡើងជាទូទៅនៅបណ្តាប្រទេសខាងត្បូង ដោយផ្អែកលើការកំនត់របស់ Robert Dahl នៅឆ្នាំ១៩៧១ គួរចាត់ទុកជា "លទ្ធិប្រជាធិបតេយ្យសន្ទុះខ្សោយ (low-intensity democracy)" ពោលគឺបណ្តាស្ថាប័នប្រជាធិបតេយ្យ "ផ្លូវការ" ដែលត្រូវបានរៀបចំឱ្យស៊ីគ្នានឹងតំរូវការនៃរបបមូលធនសាកល និងដាច់ចេញពីរបៀបវារៈយុត្តិធម៌សង្គមដែលជួយឱ្យវាមានលក្ខណៈទាក់ទាញចំពោះអ្នកក្រ ។ ប្រជាធិបតេយ្យប្រភេទនេះ វាទប់ស្កាត់ និងរាំងស្ទះ មិនមែនជួយសំរួលដល់តំរូវការនៅតាមមូលដ្ឋានឱ្យមានកំណែទំរង់សង្គមកិច្ចទូលំទូលាយនោះទេ ។ វាក៏នាំឱ្យមានការផាត់សាធារណជនចេញ ពីព្រោះការរំពឹងថានឹងមានជីវភាពប្រែប្រួលប្រសើរឡើង គឺត្រូវបរាជ័យអស់ ។ អ្នកនិពន្ធមានទស្សនៈថា ការលើកកំពស់លទ្ធិប្រជាធិបតេយ្យ គឺជាការចាប់យក "ស្តង់ដារមាសសាកល" នៃលទ្ធិប្រជាធិបតេយ្យ ដោយសារកំលាំងអនុត្តរភាពនានា (forces of hegemony) ។ (see also Robinson 1996; Abrahamsen 2000; Mkandwire 1999).

***ការយកចិត្តទុកដាក់មិនគ្រប់គ្រាន់ចំពោះអន្តរកម្មរវាងរដ្ឋ និងសង្គម:*** Kohli (1997) បានដាក់ស្នើនូវសេណារីយ៉ូមួយផ្សេងទៀត នៅក្នុង "របបប្រជាធិបតេយ្យធ្វើតាមគេ" ដោយបង្ហាញថា ស្ថាប័នប្រជាធិបតេយ្យ ដែលខ្សោយ និងនាំចូលពីក្រៅប្រទេស អាចទទួលបរាជ័យដោយសារកំលាំងសង្គមដែលផ្អែកលើលក្ខណៈផ្សេងៗនៃសហគមន៍ ដូចជា ចំនងទាក់ទងមេកើយ-កូនចៅ សាច់ញាតិ ខ្សែរយៈខាងកុលសម្ព័ន្ធ រឺអត្តសញ្ញាណជនជាតិ ។ម្យ៉ាងទៀត ការលើកកំពស់លទ្ធិប្រជាធិបតេយ្យ បានលើកទឹកចិត្តពួកឋានៈខ្ពស់ឱ្យប្រើប្រាស់លក្ខណៈសហគមន៍ទាំងនេះ ធ្វើជាមធ្យោបាយកេណ្ឌប្រមូលកំលាំងខាងនយោបាយ ដែលអាចនាំឱ្យមានការប៉ះទង្គិចអត្តសញ្ញាណ ការខូចខាតដល់រចនាសម្ព័ន្ធអាជ្ញាធរជាប្រពៃណី និងការសាបរលាបក្រឹត្យក្រមនៃសហគមន៍ ហើយទាំងអស់នេះ នឹងធ្វើឱ្យរអាក់រអួល ដល់សណ្តាប់ធ្នាប់សង្គម ។ ការឆ្លើយតបរបស់ក្រុមផ្សេងៗចំពោះបញ្ហានេះនៅក្នុងការប្រកួតគ្នាមួយដែលក្នុងនោះ គំរូនយោបាយនាំចូល និងលក្ខខណ្ឌនៃវប្បធម៌ប្រជាជនដើម វាធ្វើអន្តរកម្មទៅលើគ្នា និងសំរបខ្លួនទៅតាមគ្នាចុះឡើង នឹងជំរុញឱ្យមានចលាចលខាងនយោបាយ ។

ជំហរទាំងឡាយខាងលើនេះ យល់ស្របនឹងសារណាសន្តិភាពបែបប្រជាធិបតេយ្យ ។ ក្នុងរឿងនេះដែរ ជំនឿជាទូទៅនៅក្រោយសម័យសង្គ្រាមត្រជាក់ បានទទួលការរិះគន់នៅចុងទសវត្សរ៍១៩៩០ ។ ឯកសារប្រៀបធៀបមួយបានផុសឡើង ដែលចងភ្ជាប់អន្តរកាលនយោបាយ (ក្នុងនេះមានទាំងអន្តរកាលទៅកាន់របបប្រជាធិបតេយ្យផង) ទៅនឹងអំពើហិង្សាកំរិតខ្ពស់ជាងអ្វីដែលធ្លាប់បានពិនិត្យឃើញ នៅក្នុងរបបប្រជាធិបតេយ្យដែលបានពង្រឹងហើយ រឺរបបផ្តាច់ការដែលបានពង្រឹងហើយ (Huntington 1991; Bratton and van de Walle 1996) ។ ការសិក្សានានាពីការកសាងឡើងវិញក្រោយពេលបញ្ចប់ទំនាស់ បានផ្តល់គំនិតថា ការដាក់បញ្ចូលនយោបាយប្រកួតប្រជែងគ្នារបស់គណបក្ស ទៅក្នុងស្ថានភាពមួយដែលក្នុងនោះ ទាំងសង្គមស៊ីវិល និងស្ថាប័នរដ្ឋ នៅមិនទាន់រឹងប៉ឹងដើម្បីទប់ស្កាត់ការផ្ទុះអំពើហិង្សាថ្មីៗទៀត វាផ្តល់លទ្ធភាពឱ្យក្រុមអ្នកប្រព្រឹត្តអំពើហិង្សាអាចច្បាមយកឱកាសធ្វើសកម្មភាពបាន (Huntington 1996; Paris 2003; Ottaway 2003) ។ ឥទ្ធិពលដ៏អាក្រក់នៃការបោះឆ្នោតនៅក្នុងដំណើរការសន្តិភាពនៅប្រទេស Angola និង Rwanda ដែលនៅក្រោយពេលចុះកិច្ចព្រមព្រៀងសន្តិភាព មានប្រជាជនស្លាប់ច្រើនជាងនៅមុនពេលចុះកិច្ចព្រមព្រៀងនោះ វាបានកាត់បន្ថយតំលៃនៃការប្រើប្រាស់ដោយជោគជ័យនូវការបោះឆ្នោត ដើម្បីផ្តល់លក្ខណៈពេញច្បាប់ដល់របបគ្រប់គ្រងថ្មីៗដែលគោរពរដ្ឋធម្មនុញ្ញ ដូចជានៅប្រទេស Mozambique ជាដើម ។ ទោះបីនៅតាមកន្លែងដែលការបោះឆ្នោត បានទទួលជោគជ័យក្នុងការកេណ្ឌប្រមូលការគាំទ្រឱ្យមានលក្ខណៈពេញច្បាប់ក្តី ប៉ុន្តែគេយល់ថាវាមានជោគជ័យតិចតួចណាស់ ក្នុងការជួយសំរួលឱ្យមានការចូលរួមខាងនយោបាយ ការលើកកំពស់ការគោរពសិទ្ធិមនុស្ស និងការកាត់បន្ថយសកម្មភាពរបស់រដ្ឋនៅក្នុងបញ្ហាមួយចំនួន ដូចជា អំពើពុករលួយជាដើម ។ សរុបមកគេយល់ថាទាំងអស់នេះ ហាក់ដូចបានរក្សាទុកដដែលនូវលក្ខខណ្ឌនានាដែលនឹងបង្កឱ្យមានទំនាស់ហិង្សាទៅអនាគតទៀត ។

## ការប្រើប្រាស់ទស្សនៈកូនកាត់ ដើម្បីស្វែងយល់ពីការលូតលាស់របបប្រជាធិបតេយ្យនៅកម្ពុជា

ក្នុងប៉ុន្មានឆ្នាំកន្លងទៅ ប្រទេសកម្ពុជាហាក់មានបង្ហាញនូវលក្ខណៈជាច្រើននៃរបបប្រជាធិបតេយ្យកូនកាត់ ។ ឧទាហរណ៍ ប្រព័ន្ធអភិបាលកិច្ចខាងនយោបាយនៅកម្ពុជា បានរក្សាទំរង់មួយចំនួននៃនីតិវិធី និងស្ថាប័នជាផ្លូវការរបស់របបប្រជាធិបតេយ្យសេរី ប៉ុន្តែគុណតំលៃស្នូលនានានៃលទ្ធិប្រជាធិបតេយ្យ មិនបានជ្រាតជ្រាបចូលទៅក្នុងទំនាក់ទំនងរដ្ឋ-សង្គមទេ ។ ស្ថាប័នគន្លឹះៗ ក៏មិនទាន់មានសមត្ថភាពការពាររបបនយោបាយបែបប្រជាធិបតេយ្យ ការផ្តល់សេវាដ៏សក្តិសិទ្ធិ រឺធនធានធម្មជាតិដ៏សំខាន់ៗនោះដែរ ។ ប្រព័ន្ធដែលដំណើរការតាមខ្សែរយៈបុគ្គលជាមេកើយ ក៏បានផុសឡើងដោយបានលាយឡំប្រទាក់ក្រឡាជាមួយនឹងសេដ្ឋកិច្ចនយោបាយ ដែលស្វែង

រកប្រយោជន៍ និងស្ទើរតែមានលក្ខណៈពេញច្បាប់ហើយក៏ផ្ទេរចូលទៅក្នុងបរិបទថ្មីនៃនយោបាយមហាជនដើរតាមទីផ្សារសេរី (Hughes 2003; Un 2005) ។ ដូច្នេះហើយទំនាក់ទំនងរដ្ឋ-សង្គម អាចធ្វើឱ្យពុករលួយបាន អាចធ្វើអាជីវកម្មកេងយកប្រយោជន៍ រឺក៏គ្មានសោះតែម្ដងនៅក្នុងស្ថានភាពខ្លះ ។ ឥរិយាបថមន្ត្រីចំពោះពលរដ្ឋ និងឥរិយាបថរបស់ពលរដ្ឋចំពោះមន្ត្រី ក៏ប្រែប្រួលទៅតាមនោះដែរ ។

ចំពោះការស្រាវជ្រាវខាងគោលនយោបាយ គួរមានក្របខ័ណ្ឌមួយ ដែលក្នុងនោះ ត្រូវពិនិត្យនិងវិភាគ មិនត្រឹមតែពីចរិតនៃស្ថាប័នប្រជាធិបតេយ្យកម្ពុជា និងឥទ្ធិពលរបស់វាទៅលើនយោបាយនៅថ្នាក់ក្រោមប៉ុណ្ណោះទេ ប៉ុន្តែពីចរិតនៃនយោបាយនៅថ្នាក់ក្រោម និងឥទ្ធិពលរបស់វាទៅលើស្ថាប័នទាំងនោះទៀតផង ។ អន្តរកម្មរវាងរចនាសម្ព័ន្ធប្រជាធិបតេយ្យ និងមិនមែនប្រជាធិបតេយ្យ (ដែលមិនមែនមានតែរចនាសម្ព័ន្ធផ្ដាច់ការនោះទេ) នៃអំណាច និងរបៀបរបបអនុវត្តន៍នាបច្ចុប្បន្ននៃការចូលធ្វើនយោបាយរបស់ថ្នាក់ក្រោម បានបង្កើតជាទំនាក់ទំនងរដ្ឋ-សង្គមដ៏ស្មុគស្មាញមួយ ។ ម្យ៉ាងទៀត នៅក្នុងប្រព័ន្ធកូនកាត់ ដើម្បីវិភាគពីទំនាក់ទំនងបែបនេះ គេត្រូវធ្វើការស្រាវជ្រាវស្ទួលមួយដើម្បីកំណត់ លាតត្រដាង ស្វែងយល់ និងវិភាគពីឌីណាមិក និងឥទ្ធិពលនៃការរួមរស់ជាមួយគ្នា ព្រមទាំងទំនាក់ទំនងរវាងស្ថាប័នផ្លូវការ-ស្ថាប័នក្រៅផ្លូវការ ដំណើរការប្រជាធិបតេយ្យ-ដំណើរការមិនមែន (រឺប្រឆាំង) ប្រជាធិបតេយ្យ ការរៀបចំផ្អែកលើភាពសមហេតុផល-ផ្អែកលើប្រពៃណី ព្រមទាំងទស្សនៈវិស័យបែបនយោបាយ-បែបបច្ចេកទេស ។ ក្របខ័ណ្ឌនេះ ដែលសំរាប់ស្វែងយល់ពីទំនាក់ទំនងរដ្ឋ-សង្គម បានបង្ហាញនូវ ៣ វិស័យពាក់ព័ន្ធគ្នាសំរាប់ធ្វើការស្រាវជ្រាវឱ្យច្បាស់លាស់នៅកម្ពុជា ។

## ការអភិវឌ្ឍន៍ខាងស្ថាប័ន

ការងារនេះ ត្រូវផ្ដោតលើសមាសភាពខាងស្ថាប័នរបស់រដ្ឋ ។ ដំណើរការខាងក្នុងនៃម៉ាស៊ីនរដ្ឋ ការបែងចែកអំណាច និងតួនាទីរបស់តួអង្គផ្សេងៗ គួរយកធ្វើជាគោលដៅសំរាប់ការស្រាវជ្រាវ ។ គួរផ្ដោតជាពិសេសទៅលើការអនុវត្តន៍ និងបែបបទនៃកំណែទំរង់ស្ថាប័នសំខាន់ៗរបស់កម្ពុជា នៅក្នុងដំណើរការធ្វើវិមជ្ឈការនិងវិសហមជ្ឈការ ក្នុងនេះ មានទាំងប្រព័ន្ធបោះឆ្នោត ការផ្ដល់សេវា និងហិរញ្ញវត្ថុសាធារណៈផង ។ ដោយពិនិត្យពីបញ្ហាទាំងនេះក្នុងក្របខ័ណ្ឌប្រព័ន្ធកូនកាត់ ការស្រាវជ្រាវជាបឋមគួរស្វែងរក និងពន្យល់ពីអន្តរកម្មរវាងទិដ្ឋភាព ប្រជាធិបតេយ្យ-មិនមែនប្រជាធិបតេយ្យ ផ្លូវការ-មិនផ្លូវការ បច្ចេកទេស-នយោបាយ សមហេតុផល-ប្រពៃណី នៃនយោបាយ និងរដ្ឋបាល ។ បន្ទាប់មក គួរព្យាយាមវាយតំលៃពីឥទ្ធិពលនៃកំណែទំរង់វិមជ្ឈការនិងវិសហមជ្ឈការ ក្នុងបញ្ហាលើកកំពស់សមត្ថភាពរបស់រដ្ឋក្នុងការបង្កើត និងពង្រឹងការអនុវត្តន៍ច្បាប់ ការទាញយក និងបែងចែងទៅវិញនូវធនធាន ព្រមទាំងការបំផុសគំនិត និងកិច្ចការពារ "សីលធម៌សាធារណៈ" ។

## ទំនាក់ទំនងរដ្ឋ-សង្គម និងអន្តរការីនានា

សមត្ថភាពរដ្ឋដើម្បីបំពេញមុខងារស្នូលរបស់ខ្លួន ត្រូវកំនត់ឡើងទៅតាមការរៀបចំស្ថាប័ន ព្រមទាំងទំនាក់ទំនងរដ្ឋ-សង្គម ។ នៅកម្ពុជា មានឯកសារច្រើនណាស់បង្ហាញថា គំលាតរវាងអ្នកត្រួតត្រា និងអ្នកគេត្រួត គឺជាចំនុចខ្សោយចំបងជាប្រវត្តិសាស្ត្រ ក្នុងការបង្កើតទំនាក់ទំនងរដ្ឋ-សង្គម ដែលជួយសំរួលដល់មុខងារស្នូលរបស់រដ្ឋ និងបង្កើតបានជាគោលនយោបាយវិជ្ជមាន (Chandler 1998; Mabbet and Chandler 1996; Peang Meth 1991) ។ ការស្រាវជ្រាវពីចំនុចទាំងនេះ ផ្ដោតជាចំបងទៅលើបែបបទដែលតួអង្គ ក្នុងរដ្ឋ គេយល់ដឹងពីតួនាទីរបស់ខ្លួន វិធីដែលពួកគេព្យាយាមដោះស្រាយបញ្ហាដែលរដ្ឋមិនអាចលូកដៃបានជ្រៅ ដោយសារមានការតែងតាំងអន្តរការីផ្សេងៗ និងបែបបទដែលរឿងនេះជះឥទ្ធិពលដល់ការបង្កើត និងអនុវត្តន៍គោលនយោបាយ (ផ្លូវការ និងក្រៅផ្លូវការ) ។ ដូច្នេះត្រូវផ្ដោតការយកចិត្តទុកដាក់ទៅលើតំលាភាព គណនេយ្យភាព ភាពជាតំណាងឱ្យសាធារណជន និងការឆ្លើយតប ក៏ដូចជាការពិចារណាស៊ីជំរៅពីទំនាក់ទំនងនៃលក្ខណៈទាំងនេះទៅនឹងបទប្បញ្ញត្តិ និងនីតិវិធីជាផ្លូវការ លំនាំក្រៅផ្លូវការនៃអន្តរកម្មរវាងរដ្ឋ-សង្គម និងអន្តរការីនានា ព្រមទាំងគុណតំលៃខាងវប្បធម៌ និងក្រឹត្យក្រមផ្សេងៗដែលគ្រប់គ្រង និងកំនត់លំនាំទាំងអស់នេះ ។

## ការចូលរួមរបស់ពលរដ្ឋ

ការចូលរួមរបស់ពលរដ្ឋ ត្រូវបានកំនត់ថាជាដែនមួយ ដែលក្នុងនោះ បុគ្គល គ្រួសារ សហគមន៍ និងតួអង្គមិនមែនរដ្ឋ ធ្វើអន្តរកម្មជាមួយគ្នា និងជាមួយតំណាងរដ្ឋ ។ ម្យ៉ាងទៀត វាក៏ជាដែនដែលគ្រប់គ្រងដោយបទប្បញ្ញត្តិ និងនីតិវិធីផ្លូវការ (ការបោះឆ្នោត) ទំនាក់ទំនងក្រៅផ្លូវការ ព្រមទាំងគុណតំលៃ និងក្រឹត្យក្រមខាងវប្បធម៌ ។ ក្នុងអត្ថបទនេះ វាសំដៅដល់ការសិក្សាអំពីដំណើរការពីក្រោមឡើងលើដែលផ្ដោតលើគុណតំលៃ និងឥរិយាបថផ្សេងៗដែលគ្រប់គ្រងលើយុទ្ធសាស្ត្រនយោបាយប្រើប្រាស់ដោយសង្គមស៊ីវិលដើម្បីធ្វើការពាក់ព័ន្ធជាមួយរដ្ឋ ។ ប្រធានបទស្រាវជ្រាវជាក់លាក់មួយចំនួនអាចមានជាបញ្ហាអត្ថន័យនៃភាពជាពលរដ្ឋនៅកម្ពុជា តួនាទីនៃសង្គមស៊ីវិលក្នុងការបំពេញគំលាតរបស់រដ្ឋ ហើយនិងផលប៉ះពាល់នៃការចូលរួមតិចតួចរបស់ពលរដ្ឋនៅកម្ពុជាទៅលើសមត្ថភាពរបស់រដ្ឋក្នុងការបំពេញមុខងាររដ្ឋ ។

## សេចក្ដីសន្និដ្ឋាន

ក្របខ័ណ្ឌខាងលើ បង្ហាញពីរបៀបវារៈស្រាវជ្រាវថ្មីមួយសំរាប់ "របបកូនកាត់" ដែលផ្ដោតទៅលើទាំងនយោបាយថ្នាក់ខ្ពស់ខាងស្ថាប័ននៃអភិបាលកិច្ចបែបប្រជាធិបតេយ្យ ហើយនិងអន្តរកម្មរវាងរដ្ឋ និងកំលាំងសង្គមនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ។ វាក៏ផ្ដោតផងដែរទៅលើបញ្ហាថា តើនយោបាយបែបប្រជាធិបតេយ្យជួយជំរុញរឺទេ និងជំរុញយ៉ាងណាដល់ការផ្លាស់ប្ដូរសង្គមនៅថ្នាក់មូលដ្ឋាន ហើយការផ្លាស់ប្ដូរនេះ វាជួយជំរុញនយោបាយបែបប្រជាធិបតេយ្យវិញយ៉ាងដូចម្ដេច ។ ក្នុងក្របខ័ណ្ឌនេះ របៀបវារៈស្រាវជ្រាវសំរាប់ពិនិត្យមើលពីមធ្យោបាយផ្សេងៗ ដែលបុគ្គលធ្វើសេចក្ដីសំរេចជ្រើសរើស ព្រមទាំងចូលរួមធ្វើការពាក់ព័ន្ធជាផ្លូវការ និងក្រៅផ្លូវការជាមួយរដ្ឋ គឺត្រូវពិនិត្យមើលទាំងបទប្បញ្ញត្តិ និងនីតិវិធីជាផ្លូវការ ព្រមទាំងគុណតំលៃ និងក្រឹត្យក្រមសង្គមដែលបង្កើតបានជា វិធានមិនមែនលាយលក្ខណ៍អក្សរខាងនយោបាយនោះផង ។ វិធានមិនមែនលាយលក្ខណ៍អក្សរទាំងនេះ ជួយពន្យល់ពីជំរើសដែលបុគ្គលបានធ្វើឡើង វិធីអនុវត្តជំរើសរបស់ពួកគេ ហេតុផលដែលពួកគេសំរេចចិត្តបែបនេះ និង បែបបទដែលរដ្ឋនិងវប្បធម៌សហគមន៍ ជះឥទ្ធិពលទៅលើសេចក្ដីសំរេចចិត្តក្នុងការជ្រើសរើស ។

## ឯកសារយោង

*ឯកសារយោង សូមមើលក្នុងអត្ថបទជាភាសាអង់គ្លេស ។*